ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

លេខ 0094 អបស/ឱអបស

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ ០២ ឆ្នាំ២០០៧

## រដ្ឋមន្ត្រី ក្រសួងសុខាភិបាល

## ជំរាបមក

## លោក-លោកស្រីនាយកមន្ទីរសុខាភិបាល
## រាជធានីភ្នំពេញ និង ខេត្ត ក្នុងព្រះរាជាណាចក្រកម្ពុជា

**កម្មវត្ថុ** : ការណែនាំអនុវត្តប្រកាសលេខ ០០១៤ អបស/ឱអបស ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៩ របស់ក្រសួងសុខាភិបាល ។

**យោង** : លិខិតលេខ ០៨៩២ អបស/ឱអបស ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៦ ស្តីពីការផ្ទេរសិទ្ធិជូនមន្ទីរសុខាភិបាលរាជធានីភ្នំពេញ និងមន្ទីរសុខាភិបាលខេត្ត-ក្រុង ក្នុងការគ្រប់គ្រងត្រួតពិនិត្យ និងផ្តល់លិខិតអនុញ្ញាតបើក ឬបិទ ឬប្តូរទីតាំងឬអ្នកទទួលខុសត្រូវ និង ការបន្តសុពលភាពអាជីវកម្ម ឱសថស្ថាន ឱសថស្ថានរង "ក" និង "ខ" ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និង យោងខាងលើ ដើម្បីអនុវត្តឱ្យបានចំទិសដៅ នូវប្រកាសលេខ ០០១៤ អបស/ឱអបស ក្រសួងសូមធ្វើការណែនាំដូចខាងក្រោម :

១-រាល់ភារកិច្ចដែលពាក់ព័ន្ធនឹងការគ្រប់គ្រងត្រួតពិនិត្យ និងផ្តល់លិខិតអនុញ្ញាតបើក ឬបិទ ឬប្តូរទីតាំង ឬប្តូរ អ្នកទទួលខុសត្រូវ និងបន្តសុពលភាពអាជីវកម្មឱសថជូនឱសថស្ថាន ឱសថស្ថានរង "ក" និង "ខ" គឺបិត ក្នុងដែនសមត្ថកិច្ចរបស់មន្ទីរសុខាភិបាលរាជធានី និងមន្ទីរសុខាភិបាលខេត្តដូចធ្លាប់បានអនុវត្តកន្លងមក ។

២-ចំពោះឱសថស្ថានរង "ខ" ដែលមានស្រាប់មន្ទីរសុខាភិបាលរាជធានីភ្នំពេញ និងមន្ទីរសុខាភិបាលខេត្តអាចមានសិទ្ធិបន្តសុពលភាពជូនបាន ប៉ុន្តែពុំអាចអនុញ្ញាតឱ្យបើកថ្មីបានទេ (ច្បាប់ គ្រប់គ្រងឱសថជំពូកទី៦ មាត្រាទី ១៤)។

៣-ចំពោះលក្ខខណ្ឌក្នុងការបើក ឬបិទ ឬប្តូរទីតាំង ឬប្តូរអ្នកទទួលខុសត្រូវ ឬបន្តសុពលភាពជូនឱសថស្ថាន ឱសថស្ថានរង "ក" និង "ខ" ត្រូវអនុវត្តតាមខ្លឹមសារប្រកាសលេខ ០០១៤ អបស/ឱអបស ចុះថ្ងៃទី ១៣-០១-២០០៩ ។



ទីស្តីការក្រសួងសុខាភិបាល, លេខ ១៥១-១៥៣ វិថី កម្ពុជាក្រោម ភ្នំពេញ ទូរសារ: (៨៥៥-២៣) ៤២៦ ០៣៤ / ៤២៦ ៨៤១ ទូរស័ព្ទ: (៨៥៥-២៣) ៧២២ ៨៧៣

៤_មន្ទីរសុខាភិបាលរាជធានីភ្នំពេញ និងមន្ទីរសុខាភិបាលខេត្តត្រូវផ្តល់របាយការណ៍ប្រចាំខែអំពីចំនួនឱសថស្ថាន ឱសថស្ថានរង ដែលបានបើកមានច្បាប់ ឬអត់ច្បាប់ ឬបិទ ឬប្តូរទីតាំង ឬប្តូរអ្នកទទួលខុសត្រូវ និងបន្តសុពលភាព មកក្រសួងសុខាភិបាល (នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យនិងគ្រឿងសំអាង) ឱ្យបានទៀងទាត់ ។

ខ្ញុំសង្ឃឹមថា លោក_លោកស្រី នឹងយកចិត្តទុកដាក់អនុវត្ត តាមការណែនាំឱ្យមានប្រសិទ្ធភាពខ្ពស់ ។

សូមលោក_លោកស្រី ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

ម៉ម_ប៊ុនហេង

**<u>ចម្លងជូន</u> :**

.ខុទ្ទកាល័យក្រសួងសុខាភិបាល
.អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល
.នាយកដ្ឋានឱសថ_ចំណីអាហារ_បរិក្ខារពេទ្យ និងគ្រឿងសំអាង
.គ្រប់សាលាក្រុងភ្នំពេញ_ខេត្ត
.មន្ទីរសុខាភិបាលរាជធានីភ្នំពេញ
.គ្រប់មន្ទីរសុខាភិបាលខេត្ត
.កាលប្បវត្តិ . ឯកសារ